## តើគេនៅតែអាចអញ្ជើញទៅភោជនីយដ្ឋាន និងបារ(កន្លែងលក់ស្រា) ឬ?

ការឲ្យដកខ្លួនចេញ ហាមឃាត់អតិថិជនមិនឲ្យចូលទៅកន្លែងលេងល្បែងស៊ីសង និងបារ ឬភោជនីយដ្ឋានណាមួយរបស់ SKYCITY នៅតាមកន្លែងទាំងនោះ។ នៅ SKYCITY Queenstown នេះមានរួមទាំងកន្លែងលេងទាំងមូល។ ទោះជាយ៉ាងណាក្តី អតិថិជននៅតែអាចទៅកន្លែងបារ ភោជនីយដ្ឋាន សណ្ឋាគារ និងមណ្ឌលប្រជុំទាំងឡាយនៅក្រៅកន្លែងលេងល្បែងស៊ីសងនៅ SKYCITY Auckland និង SKYCITY Hamilton។

## តើមានការផ្គត់ផ្គង់ណាខ្លះផ្តល់ សំរាប់អស់អ្នកដែលត្រូវបានគេឱ្យដកខ្លួនចេញពីកន្លែងលេងល្បែងស៊ីសង?

SKYCITY លើកទឹកចិត្តប្រជាជនឲ្យជ្រើសតាំងអ្នកប្រៀនប្រដៅសំរាប់ផ្គត់ផ្គង់ និងអ្នកវិជ្ជាជីវៈខាងផ្តល់ឱវាទណែនាំដើម្បីណែនាំ ហើយជួយដល់គេ។ យើងមានផ្តល់បញ្ជីនៃកិច្ចបំរើផ្នែកឱវាទណែនាំដោយឥតគិតថ្លៃ រក្សាទុកជាសម្ងាត់ ហើយធ្វើការ២៤ម៉ោងក្នុង១ថ្ងៃ ដែលអាចមានជាភាសាមួយចំនួនផងដែរ។

# ខ្សែទូរស័ព្ទជំនួយលើបញ្ហាល្បែងស៊ីសង

# 0800 654 655


SKYCITY Auckland 0800 SKYCITY (0800 759 2489)

SKYCITY Hamilton 07 834 4900

SKYCITY Queenstown 03 441 0400

SKYCITY Host Responsibility
អ៊ីម៉េល: hostresponsibility@skycity.co.nz


# តើលោកអ្នកមានកង្វល់អំពីការលេងល្បែងស៊ីសងរបស់ជនណាម្នាក់ឬ?

# SKYCITY អាចជួយបាន

SKYCITY

**SKYCITY Third Party Exclusion - Khmer**

## ដំណើរការដកខ្លួនចេញ (ភាគីទីបី) SKYCITY

SKYCITY ទទួលមុខនាទីខុសត្រូវរបស់ខ្លួនក្នុងភាពជាអ្នកទទួលភ្ញៀវយ៉ាងហ្មត់ចត់ជាទីបំផុត៖ សុវត្ថិភាព និងសុខុមាលភាពនៃអតិថិជនរបស់យើងគឺជាអាទិភាពខ្ពស់បំផុត។ យើងក៏មានកាតព្វកិច្ចខាងផ្លូវច្បាប់ដ៏សំខាន់ផងដែរក្នុងភាពជាអ្នកបើកកាស៊ីណូ នៅក្រោមច្បាប់ល្បែងស៊ីសងញូវហ្សេឡង់ ឆ្នាំ២០០៣ (New Zealand Gambling Act 2003)។

ចំពោះមនុស្សខ្លះ ការលេងល្បែងស៊ីសងអាចបណ្តាលឲ្យមានការឈឺចាប់ មានរួមទាំងបញ្ហាប្រាក់កាស ការតានតឹងខាងផ្លូវចិត្ត និងការលំបាកកើតមាននៅក្នុងទំនាក់ទំនង។

ប្រសិនបើលោកអ្នកមានកង្វល់អំពីការលេងល្បែងស៊ីសងរបស់មិត្តភក្តិ ឬសមាជិកគ្រួសារនោះ SKYCITY មានបំណងចង់ដឹងពួពីលោកអ្នក។

## ខ្ញុំមានកង្វល់អំពីការលេងល្បែងស៊ីសងរបស់មិត្តភក្តិខ្ញុំ មិត្តភក្តិរបស់ខ្ញុំមិនទទួលស្គាល់ថាគេមានបញ្ហាណាមួយឡើយ។ តើ SKYCITY អាចធ្វើអ្វីខ្លះដើម្បីជួយដល់គេ?

SKYCITY មានជំរើសនៃការដកខ្លួនអតិថិជនចេញពីកន្លែងលេងល្បែងស៊ីសងនៅកាស៊ីណូញូវហ្សេឡង់របស់ខ្លួន សំរាប់រយៈពេល២ឆ្នាំ។ នេះគឺជាជំហានមួយយ៉ាងធ្ងន់ធ្ងរដែល SKYCITY ត្រូវចាត់វិធានការ ហេតុដូច្នេះហើយកាស៊ីណូមិនបានចាត់ទុកថានេះគឺជារឿងធម្មតាឡើយ។ លោកអ្នកគួរទាក់ទងជាមួយ មន្ទីរអ្នកទទួលភ្ញៀវដោយមានការទទួលខុសត្រូវរបស់ SKYCITY ដើម្បីពិភាក្សាអំពីដំណើរការនេះ។

## តើការដកខ្លួនចេញគឺជាជំរើសតែមួយឬ?

ទេ – នេះគឺជាជំហានមួយនៃជំហានមួយចំនួនដែលអាចធ្វើឡើង មានរួមទាំងការធ្វើតាមគោលការណ៏លេងល្បែងស៊ីសងដែលមានការទទួលខុសត្រូវ និងការទទួលឱវាទណែនាំផ្នែកវិជ្ជាជីវ:។ ដើម្បីទទួលយកព័ត៏មានច្រើនថែមទៀត សូមទាក់ទងជាមួយខ្សែទូរស័ព្ទជំនួយលើបញ្ហាល្បែងស៊ីសង (Gambling Helpline): 0800 654 655 ឬមើលនៅតាមវិបសាយ www.gamblingproblem.co.nz។

## តើនំរង់ការដកខ្លួនចេញពីកន្លែងលេងល្បែងស៊ីសងជាអ្វី?

យើងនឹងពិភាក្សាអំពីកង្វល់របស់លោកអ្នក ជាមួយលោកអ្នក ហើយពិនិត្យមើលឡើងវិញនូវភស្តុតាងខាងក្រៅណាមួយដែលលោកអ្នកអាចផ្តល់ (ឧទាហរណ៏ របាយការណ៏សមតុល្យគណនី វិក្កយបត្រដែលមិនទាន់បានបង់)។ បន្ទាប់មក SKYCITY នឹងរៀបចំធ្វើការតាមដានផ្ទៃក្នុងលើទម្លាប់ និងអាកប្បកិរិយាលើលេងល្បែងស៊ីសងរបស់អតិថិជន ក្នុងកាលគេកំពុងនៅកន្លែងកាស៊ីណូ។

បន្ទាប់មក SKYCITY ជ្រើសរើសជួបជាមួយអតិថិជនដើម្បីពិភាក្សាអំពីការលេងល្បែងស៊ីសងរបស់គេ។ នៅក្នុងការប្រជុំនេះ SKYCITY នឹងមិនរំលឹកប្រាប់គេឲ្យដឹងអំពីការទាក់ទងរបស់លោកអ្នកជាមួយយើងឡើយ លើកលែងតែលោកអ្នកបានផ្តល់ការអនុញ្ញាតមកយើងដើម្បីនឹងធ្វើដូច្នោះ។

ប្រសិនបើ SKYCITY ពេញចិត្តថាកង្វល់របស់លោកអ្នកគឺពិតត្រឹមត្រូវ ហើយសមរម្យគួរយកជាការបាន នោះ SKYCITY នឹងផ្តល់ឱកាសមួយដល់អតិថិជនដើម្បីឲ្យគេដកខ្លួនចេញពី SKYCITY សំរាប់រយៈពេល១ឆ្នាំ ហើយរហូតទាល់តែគេបានបំពេញទៅលើល័ក្ខខ័ណ្ឌនៃការសុំចូលលេងម្តងទៀតនៅឯកាស៊ីណូ។ ប្រសិនបើគេប្រកែកមិនទទួលយកជំរើសនេះទេ គេនឹងត្រូវបានប្រាប់ថា SKYCITY បានសំរេចដកខ្លួនគេចេញពីកន្លែងលេងល្បែងស៊ីសងចំនួនយ៉ាងតិចបំផុត២ឆ្នាំ។ ព័ត៏មានលំអិតរបស់គេនឹងត្រូវបានកត់ចុះ ហើយនឹងត្រូវគេថតជារូបថតទុក។ គោលបំណងនៃការថតរូបទុកគឺដើម្បីជួយ SKYCITY សំគាល់រូបអតិថិជន ប្រសិនបើគេសាកល្បងចូលមកលេងម្តងទៀតនៅកន្លែងលេងល្បែងស៊ីសង ក្នុងកាលត្រូវបានគេដកខ្លួនចេញ។

បន្ទាប់មក អតិថិជននឹងត្រូវគេលើកទឹកចិត្តឲ្យជ្រើសតាំងអ្នកប្រៀនប្រដៅ (គ្រួសារ /សមាជិកគ្រួសារ ឬមិត្តភក្តិ) ដែលគេអាចផ្គត់ផ្គង់ ហើយដើម្បីជ្រើសរើសយកកិច្ចបំរើផ្តល់ឱវាទណែនាំ។

ប្រសិនបើអតិថិជនមានប័ណ្ណ Action គេអាចប្តូរយកពិន្ទុរបស់គេបាន។ ប័ណ្ណរបស់គេនៅពេលនោះត្រូវបានដាក់លែងឲ្យធ្វើការកើត។

## តើនេះគឺជារឿងរក្សាទុកជាសម្ងាត់ឬ?

ដំណើរការដកខ្លួនចេញគឺជាកិច្ចបំរើមួយធ្វើឡើងដោយមានការប្រុងប្រយ័ត្នជាទីបំផុត ដែលបានចាត់ចែងឡើងឆ្ងាយផុតពីជាន់អាគារល្បែងស៊ីសង។ ព័ត៏មានដែលទទួលបានត្រូវបានរក្សាទុកជាសម្ងាត់ ហើយត្រូវគេយកប្រើប៉ុណ្ណោះដើម្បីជួយ SKYCITY ការពារអតិថិជនពីការវិលត្រឡប់មកទីកន្លែងលេងល្បែងស៊ីសងវិញ។

សូមកត់ចំណាំថាដោយព្រោះតែច្បាប់ឯកជន ឆ្នាំ១៩៩៣ (Privacy Act 1993), SKYCITY នឹងមិនអាចជំរាបលោកអ្នកអំពីការរកឃើញ ឬលទ្ធផលនៃការតាមដានផ្ទៃក្នុងរបស់អតិថិជនឡើយ។

ផ្នែករបស់លោកអ្នកនៅក្នុងដំណើរការនេះត្រូវបានរក្សាទុកដោយសម្ងាត់ - ប្រសិនបើលោកអ្នកប្រាថ្នា អតិថិជននឹងមិនបានប្រាប់ថាលោកអ្នកបានមកជួបយើង ហើយរាយការណ៏ប្រាប់អំពីកង្វល់របស់លោកអ្នកឡើយ។

## តើមានល័ក្ខខ័ណ្ឌការសុំចូលមកលេងម្តងទៀតអ្វីខ្លះ?

- មិនត្រូវឲ្យមានការបំពាននៃការឲ្យដកខ្លួនចេញពីកន្លែងលេងល្បែងស៊ីសងសំរាប់ភាគីទី៣ សំរាប់រយៈពេល៦ខែមុន ហើយនិង
- បង្ហាញឃើញភស្តុតាងថាអតិថិជនបានទៅចូលរួមក្នុងកម្មវិធីផ្តល់ឱវាទណែនាំយ៉ាងតិចណាស់ចំនួន៦ដង។

កាលណាអតិថិជនបានបំពេញល័ក្ខខ័ណ្ឌឲ្យចូលមកលេងម្តងទៀតហើយនោះ គេត្រូវការដាក់ពាក្យសុំជាផ្លូវការទៅ SKYCITY ដើម្បីសុំចូលមកលេងម្តងទៀត។ អតិថិជនមិនអាចចូលមកកន្លែងលេងល្បែងស៊ីសងបានឡើយ រហូតទាល់តែ SKYCITY បានអនុញ្ញាតយល់ព្រមលើពាក្យសុំចូលមកលេងម្តងទៀតរបស់ខ្លួន។ SKYCITY អាចជ្រើសរើសណែនាំដាក់បន្ថែមនូវល័ក្ខខ័ណ្ឌឲ្យចូលមកលេងម្តងទៀត ទៅតាមការសំរេចរបស់ខ្លួន។

## តើនឹងមានអ្វីកើតឡើងប្រសិនបើអតិថិជនសាកល្បងចូលមកកន្លែងលេងល្បែងស៊ីសង ក្នុងកាលខ្លួនកំពុងត្រូវគេដកខ្លួនចេញពីកន្លែងលេងល្បែងស៊ីសង?

អតិថិជនអាចក្រសួងកិច្ចការផ្ទៃក្នុងកាត់ទោស ហើយផាកពិន័យ។ ប្រសិនបើត្រូវគេចាប់ខ្លួនបានលើសពី១ដង នោះអតិថិជននឹងត្រូវគេចេញឲ្យនូវលិខិត “ការតម្រូវឲ្យចាកចេញពីកន្លែងលេងល្បែងស៊ីសង” (RLTP) ឬចេញលិខិតល្មើសច្បាប់ (Trespass Notice)។ ការនេះនឹងមានន័យថាអតិថិជនមិនអាចចូលមកកាន់ផ្នែកណាមួយនៃកន្លែង SKYCITY ដែលទាក់ទិននោះចំនួន២ឆ្នាំបន្ថែមទៀត។ ប្រសិនបើអតិថិជនបំពាន លិខិតល្មើសច្បាប់ នោះគេអាចត្រូវប៉ូលិសញូវហ្សេឡង់កាត់ទោស។

## តើអតិថិជននឹងនៅតែទទួលសម្ភារៈចុះផ្សាយពាណិជ្ជកម្មតាមសំបុត្រជាដដែលឬ?

ទេ។